**ការគាំទ្រសេវាអប់រំសំរាប់កុមារដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាល**

**Educational Support to Children in Underserved Populations (ESCUP)**

# កញ្ចប់ព័ត៌មានគ្រូសហគមន៍
# សំរាប់នាយកសាលា និង ប្រធានក្រុមបច្ចេកទេស
# តាមសាលារៀនបឋមសិក្សាគោលដៅ

# An Information Package of Community Teachers for the School Directors and TGLs in the Target Primary Schools

**អង្គការអប់រំពិភពលោក ខេត្តកំពង់ចាម**

**២០០៥-២០០៦**

# អារម្ភកថា

កញ្ចប់ព័ត៌មានគ្រូសហគមន៍ត្រូវបានចងក្រងឡើង សំរាប់នាយកសាលារៀន ប្រធានក្រុមបច្ចេកទេស គណៈកម្មការទ្រទ្រង់សាលារៀន ការិយាល័យអប់រំ មន្ទីរអប់រំ និង ក្រសួងអប់រំអប់រំ យុវជន និងកីឡា។ ឯកសារនេះគឺជាចំនែកតូចមួយដើម្បីអោយថ្នាក់ដឹកនាំ ឬអ្នកពាក់ព័ន្ធទាំងឡាយ ជាពិសេសសំរាប់ លោកនាយក/នាយិកា និងប្រធានក្រុមបច្ចេកទេសដែលនៅបំរើការក្នុងសាលារៀននោះផ្ទាល់បានយល់ពី ស្ថានភាព ព័ត៌មានមូលដ្ឋានមួយចំនួន និងដំណើការនៃការជ្រើសរើសគ្រូសហគមន៍អោយបំរើការនៅសាលាបឋមសិក្សារដ្ឋ។ ប៉ុន្តែយើងក៏អាចនិយាយថា វាជាជំនួយដ៏ធំមួយសំរាប់អោយថ្នាក់ដឹកនាំនៅតាមសាលារៀនបានយល់ដឹងខ្លះពខ្លឹមសារ និងព័ត៌មានផ្សេងៗទៀត ហើយធ្វើការស្វែងយល់ និងប្រៀបធៀបជាមួយអ្វីៗដែលលោកគ្រូ-អ្នកគ្រូទាំងឡាយទទួល បានពីការបណ្តុះបណ្តាលរបស់ក្រសួង រួចហើយធ្វើការបំពេញបន្ថែម គាំទ្រ និងធ្វើការសម្របសម្រួលដើម្បីអោយគ្រូសហគមន៍ ក្លាយទៅជាគ្រូបង្រៀនមួយរូបដ៏ល្អលើផ្នែក ចំនេះដឹង បំនិន និង ឥរិយាបថ ដែលជាធនធានមនុស្សដ៏ចាំបាច់បំផុតនៅក្នុងតំបន់កំពុងខ្វះខាតគ្រូបង្រៀន។

ជាការពិតណាស់ ការបណ្តុះបណ្តាលកន្លងមកគឺមានរយៈពេលខ្លីបើប្រៀបធៀបទៅនឹងការបណ្តុះបណ្តាលរបស់ក្រសួងអប់រំ ។ ប៉ុន្តែវាជាមោទនភាពមួយដែលយើងទាំងអស់គ្នាបានឈានមកដល់ដំណាក់កាលនេះ។

ដូចនេះ ការចូលរួមសហការ ការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ លោកគ្រូ/អ្នកគ្រូ នៅតាមសាលារៀនចំពោះគ្រូសហគមន៍ដើម្បីកែលំអ គឺជាការរួមចំណែកមួយយ៉ាងសំខាន់បំផុតដើម្បីអោយគុណភាពអប់រំនៅតំបន់នោះ ក៏ដូចជាការអប់រំនៅក្នុងប្រទេសកម្ពុជាទាំងមូលទទួលបាននូវ ប្រសិទ្ធភាពខ្ពស់ និងការអភិវឌ្ឍឈានឡើង។

ក្រុមអ្នកបណ្តុះបណ្តាលគ្រូរបស់គំរោងអេស្កាប់

# មាតិកា

**អារម្ភកថា**

**មាតិកា**

១. សេចក្តីជូនដំណឹងក្នុងការជ្រើសរើសគ្រូសហគមន៍.......................................................៤

២. លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសគ្រូសហគមន៍.......................................................៥

៣. ពាក្យសុំចូលបំរើការងារជាគ្រូសហគមន៍.......................................................៦

៤. កំរងសំនួរសំភាសន៍គ្រូសហគមន៍.......................................................៨

៥. សកម្មភាពក្នុងជំហានបន្ទាប់ ក្នុងការជ្រើសរើសគ្រូសហគមន៍.......................................................៩

៦. កិច្ចសន្យាការងាររបស់គ្រូសហគមន៍.......................................................១០

៧. គោលបំណង និងវត្ថុបំណងនៃវគ្គបណ្តុះបណ្តាលគ្រូសហគមន៍.......................................................១២

៨. រចនាសម្ព័ន្ធនៃកម្មវិធីបណ្តុះបណ្តាលរយៈពេល១០ថ្ងៃ.......................................................១៣

៩. ខ្លឹមសារសំខាន់ៗនៃវគ្គបណ្តុះបណ្តាលសំរាប់ថ្ងៃនីមួយៗរយៈពេល១០ថ្ងៃ.......................................................១៤

១០. បញ្ជីសម្ភាររបស់គ្រូសហគមន៍.......................................................១៨

១១. ទំរង់វាយតំលៃពាក់កណ្តាលវគ្គ.......................................................១៩

១២. ទំរង់វាយតំលៃបញ្ចប់វគ្គ.......................................................២០

១៣. មតិរបស់ក្រុមអ្នកបណ្តុះបណ្តាលថ្លែងទៅកាន់គ្រូសហគមន៍អំពី តួនាទី និង ស្ថានភាពមួយចំនួនដែលពាក់ព័ន្ធនឹងគ្រូសហគមន៍នៅពេលបញ្ចប់វគ្គ.......................................................២១

១៤. ព័ត៌មានអំពីគំរោងអេស្កាប់.......................................................២៣

# សេចក្ដីជូនដំណឹង

ដោយមានការយល់ព្រមពីក្រសួងអប់រំយុវជន និង កីឡា មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក កម្មវិធីអេស្កាប់( កម្មវិធីគាំទ្រការអប់រំដល់កុមារនៅតំបន់ដាច់ស្រយាល) រួមជាមួយកំរងសាលាមូលដ្ឋាន និង គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ ក្នុងឃុំ,,....................... .....សូមប្រកាសជ្រើសរើសបេក្ខជន ដាក់ពាក្យធ្វើជាគ្រូសហគមន៍ ដែលត្រូវបង្រៀនរយៈពេល២ឆ្នាំ នៅសាលាបឋមសិក្សា .......................... ....................... ក្នុងកំរង............................................. ចាប់ពីឆ្នាំសិក្សា ២០០៥-២០០៦ នេះទៅ ។

<u>លក្ខណៈសម្បត្តិជ្រើសរើសមានដូចខាងក្រោមៈ</u>

- យ៉ាងហោចណាស់ ជាអតីតសិស្សរៀនចប់ថ្នាក់ទី ៩ ឬ ថ្នាក់ប្រហាក់ប្រហែល
  *( ដោយឡែក ចំពោះស្រុកអូររាំងនិងកែវសីមា នៅខេត្តមណ្ឌលគីរី អាចកំរិតទាបជាងថ្នាក់ទី៩)*
- ជាអ្នករស់នៅក្នុងភូមិ ដែលចំណុះឱ្យសាលា
- ចេះភាសាពីរគឺភាសាខ្មែរនិងភាសាជនជាតិណាមួយដែលមានកុមារជនជាតិរៀននៅសាលានោះ
- ធ្លាប់មានបទពិសោធន៍ការងារអភិវឌ្ឍសហគមន៍
- ធ្លាប់មានបទពិសោធន៍ក្នុងការបង្រៀន
- មានចរិយាល្អនិងទទួលការរាប់អានពីអ្នកភូមិ
- ចូលចិត្តរៀនសូត្រអ្វីដែលថ្មី
- មានការតាំងចិត្ត បំរើការងារក្នុងរយៈពេល២ឆ្នាំ
- មានសុខភាពល្អ
- មានអាយុចាប់ពី១៨ឆ្នាំឡើងទៅ

បើបងប្អូនណាមានការចាប់អារម្មណ៍ សូមមកទាក់ទងសាកសួរព័ត៌មានបន្ថែម និងទទួលពាក្យសុំបំរើការ ងារ ដែលមានចែកជូនដោយឥតគិតថ្លៃ នៅ.................................................... រាល់ម៉ោងធ្វើការ ចាប់ពី ថ្ងៃទី,,............ ខែ,,....................... ឆ្នាំ២០០៥ នេះតទៅ ។

**ចាប់ទទួលពាក្យ ពីថ្ងៃទី,,...................ខែ,,................. ឆ្នាំ ២០០៥**

**ផុតកំនត់ទទួលពាក្យនៅថ្ងៃទី,,............ ខែ,,................. ឆ្នាំ ២០០៥ ។**

*មានតែបេក្ខជនដែលត្រូវជាប់ក្នុងបញ្ជីសង្ខេបលើកទី១ទេ ដែលត្រូវអញ្ជើញមកធ្វើការសំភាសន៍ ។*

*ទំនាក់ទំនងបន្ថែមតាមការិយាល័យទទួលពាក្យ ឬតាមទូរស័ព្ទ លេខ : ...........................*

*<u>បញ្ជាក់:</u>គ្រូសហគមន៍ដែលជាប់បំរើការងារជាមួយកម្មវិធីអេស្កាប់ នឹងបានទទួលប្រាក់ឧបត្ថម្ភ ចំនួន ១៨ដុល្លា ក្នុង១ខែ ហើយគិត៩ខែក្នុង១ឆ្នាំសិក្សា ។*

**សូមអរគុណ**

# លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសគ្រូសហគមន៍

| លរ. | *ករិតស្តង់ដាពិន្ទុតាមតំបន់ ដែលគណៈកម្មការសម្រេចកំនត់ ក្នុងការបង្កើតបញ្ជីលើកទី១* | | | |
|---|---|---|---|---|
| | **លក្ខណៈវិនិច្ឆ័យ** | ១ | ២ | ៣ |
| ១ | យ៉ាងហោចណាស់ ជាអតីតសិស្សរៀនចប់ថ្នាក់ទី ៩ ឬ ថ្នាក់ប្រហាក់ប្រហែល *(ស្រុកអូររាំងនិងកែវសីមា នៅខេត្តមណ្ឌលគីរី អាចករិតទាបជាងថ្នាក់ទី៩)* | | | |
| ២ | ជាអ្នករស់នៅក្នុងភូមិ ដែលចំណុះឱ្យសាលា | | | |
| ៣ | ចេះភាសាពីរគឺភាសាខ្មែរ និងភាសាជនជាតិណាមួយ ដែលមានកុមារជនជាតិរៀននៅសាលានោះ (សម្រាប់តំបន់ដែលមានកុមារជនជាតិ) | | | |
| ៤ | ធ្លាប់មានបទពិសោធន៏ការងារអភិវឌ្ឍសហគមន៍ | | | |
| ៥ | ធ្លាប់មានបទពិសោធន៏ក្នុងការបង្រៀន | | | |
| ៦ | មានចរិយាល្អនិងទទួលការរាប់អានពីអ្នកភូមិ | | | |
| ៧ | ចូលចិត្តរៀនសូត្រអ្វីដែលថ្មី | | | |
| ៨ | មានការតាំងចិត្ត បំរើការងារក្នុងរយៈពេល២ឆ្នាំ | | | |
| ៩ | មានសុខភាពល្អ | | | |
| ១០ | បេក្ខជនជានារី គួរមានអាទិភាពក្នុងការជ្រើសរើស ដើម្បីបង្ហាញគំរូល្អ ដល់កុមារីក្នុងភូមិ | | | |
| | *សរុបពិន្ទុ* | | | |

*<u>សំគាល់:</u> មានលក្ខណៈសម្បត្តិមួយចំនួនទៀត ដែលនឹងត្រូវបញ្ចូលនៅក្នុងការសម្ភាសន៏ផ្ទាល់មាត់ ដូចជា:*

- ❑ *មានភាពវាងវៃក្នុងការងារ*
- ❑ *មានចិត្តស្រឡាញ់កុមារ*
- ❑ *ស្មោះត្រង់ចំពោះការងារ*
- ❑ *មានការព្យាយាមធ្វើការងារ សិក្សាស្រាវជ្រាវនិងរៀនសូត្រពីអ្នកដែលមានបទពិសោធន៏ ។*
- ❑ *ចេះបត់បែននិងច្នៃប្រឌិត*
- ❑ *មានទំនាក់ទំនងល្អនៅក្នុងភូមិ ។*

# ពាក្យសុំចូលបំរើការងារជាគ្រូសហគមន៍

**១. <u>ព័ត៌មានទូទៅ:</u>**

នាងខ្ញុំ / ខ្ញុំបាទ ឈ្មោះ ---------------------- ភេទ --------- អាយុ ----------------

សញ្ជាតិ ------------ សាសនា ----------------- ស្ថានភាពសុខភាព: ----------------

ស្ថានភាពគ្រួសារ ☐ នៅលីវ ☐ រៀបការ ☐ ពោះម៉ាយ / មេម៉ាយ

មានកូនក្នុងបន្ទុក ☐ មាន( ចំនួន--------នាក់) ☐ គ្មាន

មុខរបរសព្វថ្ងៃ: ------------------------------------------------------------

ទីលំនៅសព្វថ្ងៃ: ភូមិ--------------ឃុំ--------------ស្រុក -----------ខេត្ត ----------

មានបំនងប្តូរទីលំនៅ: ☐ មាន ( ពេលណា?----------) ☐ គ្មាន ☐ មិនទាន់ដឹង

**២. <u>កំរិតវប្បធម៌ទូទៅ:</u>**

☐ ថ្នាក់ចុងក្រោយបង្អស់:------------------- ឆ្នាំដែលឈប់រៀន: -----------

☐ ចំណេះដឹងផ្នែកភាសា ( ភាសាជនជាតិ) ផ្សេងទៀត ក្រៅពីភាសាខ្មែរ:

| ភាសា | និយាយ | | | | សរសេរ | | | | អាន | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ល្អ | ល្អង្គួរ | មធ្យម | ខ្សោយ | ល្អ | ល្អបង្គួរ | មធ្យម | ខ្សោយ | ល្អ | ល្អបង្គួរ | មធ្យម | ខ្សោយ |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

**៣. <u>ជំនាញផ្សេងៗដែលមាន:</u>** ☐ មាន ☐ គ្មាន បើមានសូមបញ្ជាក់:

☐ ភ្លេងបុរាណ ☐ កាត់សក់ ☐ តុបតែងសំអាងការ ☐ ជួសជុលកង់ ☐ ជួសជុលម៉ូតូ ☐ កាត់ដេរ

☐ សិប្បកម្ម / ផ្សេងៗ( សូមបញ្ជាក់) :------------------------------------------

**៤. <u>បទពិសោធន៍ការងារ:</u>** ☐ មាន ☐ គ្មាន បើមានសូមបញ្ជាក់:

☐ ធ្លាប់ជាគ្រូះបង្រៀនសាលាណា?--------ឆ្នាំណា?-------- ឈ្មោះអ្នកដឹងឮ-------------

☐ ការងារសហគមន៍ : ធ្វើអ្វី?--------- ឆ្នាំណា?-------- ឈ្មោះអ្នកដឹងឮ-------------

☐ ផ្សេងៗ( សូមបញ្ជាក់) :----------------------------------------------

**៥. <u>ធ្លាប់ជាសមាជិកនៃសមាគមណាដែរឬទេ?</u>** ☐ ធ្លាប់( សមាគមអ្វី?---------------) ☐ ទេ

**៦. <u>តើហេតុអ្វីបានជាអ្នកចាប់អារម្មណ៍លើការងារនេះ?</u>**----------------------------------------------

-----------------------------------------------------------------------------------------------

-------------------------------------------------------------- ។

**បានឃើញ និង បញ្ជាក់ថាឈ្មោះខាងលើនេះ** ធ្វើនៅ________________________ ថ្ងៃទី_____________ ខែ

_________________ ឆ្នាំ ___________

**ពិតជាមានទីលំនៅក្នុងភូមិ ឃុំ ស្រុក ខាងលើពិតមែន។** ហត្ថលេខា និងឈ្មោះសាមុីខ្លួន

**ធ្វើនៅ________________________ ថ្ងៃទី_____________ ខែ ________________ ឆ្នាំ ___________**

ហត្ថលេខា និង ឈ្មោះប្រធានភូមិ-----------------

**កំរង:**............................................

**ភូមិ:**............................................ **ឃុំ:**................................................

# គំរូសំណួរសំភាសន៍គ្រូសហគមន៍

**(រយៈពេល ៥០នាទី សម្រាប់បេក្ខជនម្នាក់)**

ឈ្មោះបេក្ខជនៈ ............................................................ កាលបរិច្ឆេទៈ..........................

ឈ្មោះអ្នកសំភាសន៍ៈ ..................................................... ម៉ោងៈ.....................................

*សំគាល់ៈ* ***4****: ល្អណាស់* *3: ល្អ* ***2****: មធ្យម* ***1****: ក្រោមមធ្យម*

*មុនពេលចាប់ផ្តើមសួរសំណួរ អ្នកសំភាសន៍គួរណែនាំខ្លួន ហើយសួរបេក្ខជនថា តើគេបានដឹងអ្វីខ្លះពីកម្មវិធីអស្ចារ្យ ។ គួរឆ្លៀតពេល ប្រម៉ាណ៣-៥ នាទី ពន្យល់ពីកម្មវិធីអស្ចារ្យឱ្យបេក្ខជនបានដឹង ។*

| | សំណួរ | ពិន្ទុ | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| **ចំណាប់អារម្មណ៏ទូទៅ *(10នាទី)*** | | | | | |
| ១ | តើអ្វីទៅដែលទាក់ទាញអ្នក ឱ្យចាប់អារម្មណ៏ចង់ធ្វើជាគ្រូសហគមន៏ ? | | | | |
| ២ | តើអ្វីខ្លះទៅដែលជាបញ្ហាចំបងៗ ទាក់ទងទៅនឹងការអប់រំកុមារ នៅក្នុងមូលដ្ឋានភូមិឃុំរបស់អ្នក? | | | | |
| ៣ | តើអ្នកយល់ថាកុមារក្រីក្រ កុមារី កុមារជនជាតិ និងកុមារពិការ គួរតែមានឱកាសបានរៀនសូត្រដូចកុមារឯទៀតៗដែរឬទេ? ហេតុអ្វី? | | | | |
| ៤ | តើអ្នកយល់ថាគួរធ្វើយ៉ាងណា ដើម្បីឱ្យកុមារគ្រប់ៗរូបដែលគ្រប់អាយុ បានចូលរៀន ហើយនៅរៀនបន្តរហូតចូលវិទ្យាល័យ? | | | | |
| **បទពិសោធន៏ការងារ *(20នាទី)*** | | | | | |
| ៥ | តើអ្នកកំពុងប្រកបមុខរបរអ្វី សព្វថ្ងៃនេះ?<br>(បើមាន តើអ្នកលៃពេលវេលាដូចម្តេច រវាងការងារបច្ចុប្បន្ននិងការបង្រៀន?) | | | | |
| ៦ | តើអ្នកគិតថា អ្នកមានចំនេះដឹង ជំនាញ ឬបទពិសោធន៏អ្វីខ្លះ ដែលរួមចំនែកជួយដល់ការបង្រៀនរបស់អ្នក? | | | | |
| ៧ | តើអ្នកធ្លាប់បានបង្រៀនកុមារដែរឬទេ?បើធ្លាប់ តើបង្រៀននៅឯណា? ប្រើវិធីសាស្ត្រអ្វី? | | | | |

| | | | | | |
|---|---|---|---|---|---|
| ៨ | តាមការយល់ឃើញរបស់អ្នក តើគ្រូគួរធ្វើដូចម្តេច ដើម្បីបង្រៀនកុមារឱ្យឆាប់យល់? | | | | |
| ៩ | តើអ្នកយល់ថាគួរធ្វើដូចម្តេចឱ្យកុមារជនជាតិ ដែលចេះភាសាខ្មែរតិចតួច មានចិត្តចង់រៀន? | | | | |
| **បុគ្គលិកលក្ខណៈ /អាកប្បកិរិយា *(10នាទី)*** | | | | | |
| ១០ | តើអ្នកយល់ថា វិធីណាខ្លះដែលអាចជួយរូបអ្នកឱ្យក្លាយជាគ្រូល្អបាន? | | | | |
| ១១ | តើអ្នកធ្វើដូចម្តេចនៅពេលបង្រៀន បើសិស្សសួរសំណួរមួយដែលអ្នកនឹកមិនឃើញហើយឆ្លើយមិនបាន? | | | | |
| ១២ | បើយើងជួបអ្នកភូមិណាម្នាក់ដែលស្គាល់អ្នកជិតស្និទ្ធ ហើយសួរគាត់អំពីរូបអ្នក តើអ្នកគិតថាគាត់នឹងនិយាយប្រាប់យើងដូចម្តេចខ្លះ? | | | | |
| ១៣ | តើទៅអនាគត អ្នកមានផែនការចង់ធ្វើអ្វី? | | | | |
| **សំនួរផ្សេងទៀតដែលគណៈកម្មការសំភាសន៍អាចសួរ*(5នាទី)***<br>• តើអ្នកយល់យ៉ាងណាចំពោះប្រាក់ខែ ដែលកំនត់?<br>• បើយើងត្រូវការប្រវត្តិរូបសង្ខេបរបស់អ្នក តើអាចផ្តល់ឱ្យយើងបានឬទេ?<br>• តើអ្នកមានសំណួរអ្វីចង់សួរយើងវិញឬទេ? | | | | | |
| *ពិន្ទុសរុប* | | | | | |

**លទ្ធផលនៃការសំភាសន៍ (យោបល់រួម):**

## សកម្មភាពក្នុងជំហានបន្ទាប់ ក្នុងការជ្រើសរើសគ្រូសហគមន៍

- បើកប្រាក់បុរេប្រទាន ដើម្បីប្រតិបត្តិការងារ ។
- ប្រជុំថ្នាក់ភូមិ/ឃុំ ដើម្បីផ្សព្វផ្សាយពីការជ្រើសរើសគ្រូសហគមន៍ ( ប្រសិនបើកំរង យល់ថាចាំបាច់ត្រូវប្រជុំ) ។
- ធ្វើទំនាក់ទំនងជាមួយវត្តអារាម ព្រះសង្ឃ និង អាចារ្យវត្ត ។
- *ធ្វើទំនាក់ទំនងជាមួយវិហារឥស្លាម និង អ៊ីម៉ាំ(IMAM) (ចំពោះកំរងដែលមានជនជាតិឥស្លាមច្រើន) ។*
- *ធ្វើទំនាក់ទំនងជាមួយចាស់ទុំក្នុងភូមិ ឬមេកន្រ្ទាញ ចំពោះកំរងដែល មានជនជាតិភាគតិច ។*
- ផ្សាយដំណឹងជ្រើសរើស ។
- ទទួលពាក្យ និង ប្រមូលពាក្យសុំបំរើការងារ ។ ធ្វើបញ្ជីឈ្មោះបេក្ខជនដែលបានដាក់ពាក្យសុំបំរើការងារ ។
- ធ្វើបញ្ជីរាយនាមបេក្ខជនដែលត្រូវសំភាសន៍ ។
- កំនត់ថ្ងៃអញ្ជើញបេក្ខជនមកសំភាសន៍ ។
- រៀបចំទំរង់ទាំងអស់ដែលត្រូវប្រើ ។
- ធ្វើការសំភាសន៍បេក្ខជនដែលជាប់ឈ្មោះក្នុងបញ្ជីសង្ខេប ។
- គណៈកម្មការជ្រើសរើស ធ្វើការបូកសរុបពិន្ទុនិងជ្រើសរើសបេក្ខជន ។
- ស្រង់ឈ្មោះអ្នកជាប់ ហើយបញ្ជូនបញ្ជីឈ្មោះគ្រូសហគមន៍ដែលបានជ្រើសរើសទៅការិយាល័យអប់រំ /ក្រុមការងារថ្នាក់ខេត្ត ( ភ្ជាប់ជាមួយនូវពាក្យសុំរបស់បេក្ខជនដែលជាប់ ហើយរក្សាទុកឯកសារផ្សេងៗទៀតទាក់ទងនឹងការជ្រើសរើសនៅកំរងសាលា រួមមានដូចជាពាក្យសុំនិងលទ្ធផលសំភាសន៍ របស់បេក្ខជនដែលបានដាក់ពាក្យទាំងអស់ជាដើម ។
- ទូទាត់ប្រាក់បុរេប្រទាន ។
- ជួបជាមួយគ្រូសហគមន៍ ដើម្បីចុះកិច្ចសន្យា ។
- ផ្តល់ព័ត៌មានដល់គ្រូសហគមន៍ អំពីថ្ងៃបើកវគ្គបំប៉ន ដែលផ្តល់ដោយអេស្កាប់ អញ្ជើញពួកគេឱ្យចូលរួមក្នុងវគ្គនោះ ។

WORLD EDUCATION

**World Education, Inc.**
No. 37 Street 105, Sangat Boeung Prolit, Khan 7 Makara
PO Box 74, Phnom Penh, Cambodia
Tel: (855-23) 216-854; email: worldedcam@online.com.kh
& kurtb.worlded@online.com.kh

# កិច្ចសន្យាការងារ

លោក/លោកស្រី.......................................

កម្មវិធីអេស្កាប់ មានសេចក្តីរីករាយនឹងធ្វើកិច្ចសន្យាជាមួយលោក/អ្នក ធ្វើជាគ្រូសហគមន៍ក្នុង កម្មវិធីអេស្កាប់ នៅខេត្ត..........................ដែលមានប្រសិទ្ធភាពចាប់ពី ដើម ខែ វិច្ឆិកា ឆ្នាំ២០០៥ រហូត ដល់ខែ ដំណាច់ខែកក្កដា ឆ្នាំ ២០០៧ ក្រោមល័ក្ខខ័ណ្ឌ ការងារដូចខាងក្រោម ។សូមអានល័ក្ខខ័ណ្ឌ កិច្ចសន្យា របស់លោក/អ្នក ដោយប្រុងប្រយ័ត្ន ប្រសិនបើលោក/អ្នកយល់ព្រមគោរពតាមល័ក្ខខ័ណ្ឌការងារទាំងនេះ សូមចុះហត្ថលេខា និងបរិច្ឆេទលើទំព័រខាងក្រោយ បង្អស់នៃកិច្ចសន្យា ។

**<u>ល័ក្ខខ័ណ្ឌការងារ</u>**

**ក-ទីកន្លែង ម៉ោងធ្វើការ និងការគ្រប់គ្រង:**

**ក១**-លោក/អ្នកនឹងត្រូវបង្រៀននៅសាលាបឋមសិក្សា......................................ថ្នាក់ដែលត្រូវបង្រៀន និង ត្រូវទទួលបន្ទុក គឺផ្អែកទៅតាមការចាត់តាំង ដែលនឹងត្រូវកំនត់ជាក្រោយ ។

**ក២**-លោក/អ្នកនឹងត្រូវបង្រៀនទៅតាមពេលវេលា ដូចគ្នានឹងគ្រូក្របខ័ណ្ឌក្នុងសាលា គឺអាចបង្រៀន ពេលព្រឹក ឬពេលល្ងាច ទៅតាមតំរូវការជាក់ស្តែងរបស់សាលា។ ក្រៅពីការបង្រៀន លោក/អ្នកនឹងត្រូវ ចូលរួមក្នុងវគ្គបំប៉ននិងការប្រជុំបច្ចេកទេសប្រចាំខែ ព្រមទាំងការងារមួយចំនួនទៀតដែលជាភារកិច្ចទូទៅ របស់គ្រូបង្រៀន ដូចជាការគ្រប់គ្រងថ្នាក់ រៀន ការធ្វើទំនាក់ទំនងជាមួយមាតាបិតា ការរួមចំណែក ថែរក្សាសម្បត្តិសាលារៀនជាដើម ។ល។

**ក៣**-លោក/អ្នកនឹងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសនិងរដ្ឋបាល របស់នាយកសាលា។ ក្នុងនោះដែរ គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ មានតួនាទីត្រួតពិនិត្យនិងគាំទ្រការងាររបស់ លោក/អ្នក លើផ្នែកមួយចំនួនទាក់ទងជាពិសេសទៅនឹងការងាររដ្ឋបាល ដូចជាបញ្ហាវត្តមានគ្រូនិងសិស្សជាដើម ដោយមានការសហការជាមួយ នាយកសាលា។

**ខ-ប្រាក់ឧបត្ថម្ភ :** លោក/អ្នកនឹងទទួលប្រាក់ឧបត្ថម្ភចំនួន ១៨ ដុល្លា ក្នុងមួយខែ ហើយបើកនៅរៀងរាល់ដំណាច់ខែ និមួយៗ ដោយគិត៩ខែ ក្នុង១មួយឆ្នាំសិក្សា។

**គ-ការពិពណ៌នាអំពីការទទួលខុសត្រូវ :** ការងារដែលលោកអ្នកត្រូវទទួលខុសត្រូវ មានចែងក្នុងចំនុចក២។ លោក/អ្នកក៏នៅមានការទទួលខុសត្រូវខ្លះទៀត ដែលពុំបានបញ្ចូលក្នុងការពិពណ៌នានេះ ។

**គ១-ការបញ្ឈប់ពីការងារ:** កម្មវិធីអេស្កាប់នឹងពិគ្រោះយោបល់ជាមួយគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នា ថ្នាក់ឃុំ និងគណៈកម្មការកំរងមូលដ្ឋាន ដើម្បីធ្វើការពិនិត្យ ពិភាក្សាគ្នាទៅលើការសុំឈប់ ឬបញ្ឈប់ការងាររបស់លោក/អ្នក ក្នុងអំឡុងពេលនៃកិច្ចសន្យា ក្នុងករណី ដែលលោក/អ្នកមិនអាចទទួលខុសត្រូវក្នុងការងារ ឬបង្កអោយមានបញ្ហាប៉ះ ពាល់ដល់ការងាររបស់កម្មវិធី ដោយស្នើយោបល់ទៅក្រុមការងារថ្នាក់ខេត្ត ដើម្បីសម្រេច។

**គ២-រយៈពេលនៃកិច្ចសន្យា:** កិច្ចសន្យានេះមានរយៈពេលពីរឆ្នាំ គឺគិតតាមកាលបរិច្ឆេទដែលបាន កំនត់ ក្នុងកថាខ័ណ្ឌខាងលើ។ <u>នៅពេលកិច្ចសន្យាត្រូវបានបញ្ចប់ក្រោយពីបំរើការងាររយៈពេលពីរឆ្នាំ សាម៉ីខ្លួន នឹងត្រូវរំសាយពីការងារ ហើយត្រូវបានជំនួសដោយគ្រូក្របខ័ណ្ឌ ដែលចេញពីសាលាគរុកោសល្យ។</u>

ខ្ញុំបានអានកិច្ចសន្យានេះ ហើយខ្ញុំមានបំនងយល់ព្រមទទួលយកនូវរាល់ល័ក្ខខ័ណ្ឌដែលមាន ហើយ ខ្ញុំយល់ព្រមអនុវត្តតាមល័ក្ខខ័ណ្ឌទាំងនោះ ។

| | |
|---|---|
| ហត្ថលេខានិងឈ្មោះប្រធានភូមិ | ហត្ថលេខានិងឈ្មោះសាម៉ីខ្លួន |
| ថ្ងៃទី........ខែ..............ឆ្នាំ២០០៥ | ថ្ងៃទី........ខែ..............ឆ្នាំ២០០៥ |
| ហត្ថលេខានិងឈ្មោះមេឃុំ | ហត្ថលេខានិងឈ្មោះនាយកសាលា |
| ថ្ងៃទី........ខែ..............ឆ្នាំ២០០៥ | ថ្ងៃទី........ខែ..............ឆ្នាំ២០០៥ |
| ហត្ថលេខានិងឈ្មោះតំណាងក្រុមការងារថ្នាក់ខេត្ត | ហត្ថលេខានិងឈ្មោះអ្នកសម្របសម្រួលថ្នាក់ខេត្ត<br>កម្មវិធីអេស្កាប់ |
| ថ្ងៃទី........ខែ..............ឆ្នាំ២០០៥ | ថ្ងៃទី........ខែ..............ឆ្នាំ២០០៥ |

# គោលបំណង និង វត្ថុបំណងនៃវគ្គបណ្ដុះបណ្ដាលគ្រូសហគមន៍

**គោលបំណង**

ធ្វើការបណ្ដុះបណ្ដាល គ្រូសហគមន៍ដើម្បីអោយពួកគេក្លាយទៅជាគ្រូបង្រៀននៅសាលាបឋមសិក្សារដ្ឋ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**វត្ថុបំណង**

នៅពេលបញ្ចប់វគ្គបណ្ដុះបណ្ដាល សិក្ខាកាមនឹង...

- ស្គាល់ពីតួនាទី និងភារកិច្ចរបស់គ្រូបង្រៀននៅក្នុងសាលាបឋមសិក្សារដ្ឋ។
- អាចអនុវត្តទ្រឹស្ដីនៃការសិក្សា និងការរីកចំរើនលូតលាស់របស់កុមារ នៅក្នុងការបង្រៀនក្នុងថ្នាក់រៀន។
- អាចប្រើប្រាស់បច្ចេកទេសទាំង៤ តាមបែបសិស្សមជ្ឈមណ្ឌល ដោយផ្អែកលើឯកសារបណ្ដុះបណ្ដាលប្រធានក្រុមបច្ចេកទេស (TGL) របស់ក្រសួងអប់រំ យុវជន និងកីឡា។
- យល់ដឹងពីខ្លឹមសារនៃកម្មវិធីសិក្សានៅបឋមសិក្សា។
- អាចប្រើប្រាស់សៀវភៅសិស្ស និង សៀវភៅគ្រូរបស់ក្រសួង ក្នុងការធ្វើកិច្ចតែងការ ការបង្រៀន និងការវាយតំលៃការសិក្សារបស់ សិស្សនៅក្នុងថ្នាក់រៀន។
- យល់ដឹងពីទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ រួមទាំងដឹងពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ.

**អេស្កាប់/ESCUP  គ្រូសហគមន៍**

**រចនាសម្ព័ន្ធនៃកម្មវិធីបណ្តុះបណ្តាលរយៈពេល ១០ថ្ងៃ**

| ថ្ងៃ | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | ថ្ងៃទី៤ | ថ្ងៃទី៥ | ថ្ងៃទី៦ | ថ្ងៃទី៧ | ថ្ងៃទី៨ | ថ្ងៃទី៩ | ថ្ងៃទី១០ |
|---|---|---|---|---|---|---|---|---|---|---|
| **ប្រធានបទ** | ការសិក្សារបស់កុមារ | ការចំរើនលូតលាស់របស់កុមារ | កម្មវិធីសិក្សាបឋមសិក្សារបស់ក្រសួង<br>សៀវភៅសិស្ស<br>សៀវភៅគ្រូ<br><br>ការគាំទ្រពីTGL.<br>ប្រព័ន្ធ ESCUP | ការរៀបចំសំរាប់ការបង្រៀន<br><br>មេរៀន...<br>ការធ្វើកិច្ចតែងការការបង្រៀន<br>ការវាយតំលៃការសិក្សា | បច្ចេកទេសបង្រៀន TGLទី១-ការសួរសំនួរ<br><br>កិច្ចការអនុវត្ត | បច្ចេកទេសបង្រៀន TGL ទី២-ការគ្រប់គ្រងថ្នាក់រៀន<br><br>កិច្ចការអនុវត្ត | បច្ចេកទេសបង្រៀន TGLទី៣-បរិស្ថាន<br>កិច្ចការអនុវត្ត<br><br>បច្ចេកទេសបង្រៀន TGL ទី៤- ការប្រើភាសា របស់កុមារ<br>កិច្ចការអនុវត្ត | ការអនុវត្តបច្ចេកទេសទាំង៤ ក្នុងការធ្វើកិច្ចតែងការ និងការបង្រៀន<br><br>កិច្ចការអនុវត្ត | ការងារនៅក្នុងប្រព័ន្ធអប់រំកម្ពុជាទី១<br><br>កិច្ចការនៅក្នុងថ្នាក់រៀន | ការងារនៅក្នុងប្រព័ន្ធអប់រំកម្ពុជាទី២<br><br>សាលារៀន និង សហគមន៍ |

កញ្ចប់សំរាប់ប្រធានក្រុមបច្ចេកទេស TGL

**កំណត់សំគាល់:**

- វគ្គបណ្តុះបណ្តាលនេះគឺ សំរាប់គ្រូសហគមន៍ដែលមិនធ្លាប់ធ្វើជាគ្រូបង្រៀនពីមុនទាល់តែសោះ។ ពេលបណ្តុះបណ្តាលចប់គ្រូទាំងនេះត្រូវបំរើការនៅក្នុងសាលារដ្ឋ ដែលជាវិធានការបណ្តោះអាសន្នមួយសំរាប់ដោះស្រាយ បញ្ហាខ្វះខាតគ្រូបង្រៀនជាចំបង។ ពួកគាត់ត្រូវបំរើការរយៈពេល២ឆ្នាំ រហូតដល់គរុសិស្សដែលបានបណ្តុះបណ្តាល នៅសាលាគរុកោសល្យ បានបញ្ចប់ការសិក្សាហើយវិលត្រឡប់មកធ្វើជាបុគ្គលិកជំនួសវិញ។
- គ្រូឧទ្ទេសរបស់អេស្កាប់នឹងផ្តល់នូវការបណ្តុះបណ្តាលនេះ ដែលនឹងបង្ហាញពីគំនិតក្នុងការបង្រៀននិងរៀនរបស់កុមារ កម្មវិធីសិក្សារបស់ក្រសួងនិងសម្ភារគាំទ្រកម្មវិធី គោលវិធីជាក់ស្តែង ផ្សេងៗទៀតលើការបង្រៀន និងរៀននៅបឋមសិក្សា និងព័ត៌មានមូលដ្ឋានអំពីតួនាទី និងភារកិច្ច របស់គ្រូបង្រៀន នៅក្នុងប្រព័ន្ធអប់រំរដ្ឋ។ កម្មវិធីសិក្សានេះអាចជាប្រភពដ៏មាន ប្រយោជន៍សំរាប់ការជ្រើសរើសគ្រូដែលមានភាពបន្ទាន់ផ្សេងៗទៀតក្នុងអនាគតកាលឬសំរាប់គ្រូកិច្ចសន្យាដែលត្រូវបំរើការនៅសាលារៀនដាច់ស្រយាល់នៅក្នុងប្រព័ន្ធអប់រំរបសប្រទេសកម្ពុជា។

# ខ្លឹមសារសំខាន់ៗសំរាប់ការបណ្តុះបណ្តាលរយៈពេល១០ថ្ងៃ

| ថ្ងៃ | | | | ទំព័រ |
|---|---|---|---|---|
| ១ | | គោលបំណង និងវត្ថុបំណង នៃវគ្គបណ្តុះបណ្តាលរយៈពេល១០ថ្ងៃ | | ៧ |
| ១ | | សេចក្តីសង្ខេបអំពីរចនាសម្ព័ន្ធ នៃវគ្គបណ្តុះបណ្តាលរយៈពេល១០ថ្ងៃ | | ៨ |
| | **ដំណាក់កាលបង្រៀន** | **ខ្លឹមសារប្រធានបទ នៃវគ្គបណ្តុះបណ្តាលរយៈពេល១០ ថ្ងៃ** | **រយៈពេល** (នាទី) | |
| ១ | ១ | ១ក. ការណែនាំអំពីក្រុមសម្របសម្រួល និងគ្រូសហគមន៍<br>១ខ. ការណែនាំអំពីវគ្គសិក្សា | ៦០ | ៩ |
| | ២ | របៀបកុមាររៀន (VIPP)<br>តើកុមារបានដឹងអ្វីខ្លះមុននឹងពួកគេចូលសាលារៀន?<br>តើពួកគេរៀនអ្វីៗទាំងនោះដោយរបៀបណា? | ៩០ | ១០ |
| | ៣ | ប្រភេទនៃការសិក្សា-ចំណេះដឹង បំនិន ឥរិយាបទ/តំលៃ | ៦០ | ១១ |
| | ៤ | កុមារទាំងអស់គឺខុសប្លែកពីគ្នា (VIPP)<br>តើអ្វីទៅដែលធ្វើអោយកុមារមានលក្ខណៈដូចនោះ? | ៦០ | ១២ |
| | ៥ | ការយល់ដឹង និងការបង្រៀនសិស្សមានលក្ខណៈខុសៗគ្នានៅក្នុងថ្នាក់ រៀន | ៤៥ | ១២ |
| | | | **៥.១៥** | |
| ២ | ១ | ដំណាក់កាល លូតលាស់របស់កុមារ រហូតដល់អាយុ១១ឆ្នាំ<br>មូលហេតុចាំបាច់ដែលតំរូវអោយគ្រូត្រូវស្វែងយល់ពីការលូតលាស់របស់កុមារ | ៧៥ | ១៥ |
| | ២ | ដំណាក់កាល នៃការសិក្សារបស់កុមារៈ ភាពឃើញជាក់ស្តែង-និមិត្តសញ្ញា-អរូបី | ៦០ | ១៧ |
| | ៣ | តួនាទី ភាសា ក្នុងការសិក្សាៈ ការប្រើប្រាស់វិធី ធ្វើ (do) ពិភាក្សា (talk) កត់ត្រា (record) | ៧៥ | ១៩ |
| | ៤ | ការកសាងបន្ថែមទៅលើអ្វីដែលសិស្សបានដឹងនៅពេលបង្រៀន ខ្លឹមសារឬបញ្ញត្តិថ្មី | ៩០ | ២១ |
| | ៥ | ការអាន "ការសួរបំផុសគំនិតរបស់កុមារ" ដកស្រង់ពី TGL | ៣០ | ២៣ |
| | ៦ | ការវាយតំលៃការសិក្សា<br>តើយើងដឹងដោយរបៀបណាថា សិស្សបានរៀនអ្វីមួយ? | ៦០ | ២៣ |
| | ៧ | ការត្រួតពិនិត្យឡើងវិញ នូវខ្លឹមសារសំខាន់ៗ នៅថ្ងៃទី១ និង ថ្ងៃទី២ | ១៥ | ២៤ |

| | | | | |
|---|---|---|---|---|
| | | | ៦.៤៥ | |
| ៣ | ១ | កម្មវិធីសិក្សានៅសាលាបឋមសិក្សាកម្ពុជា-ផ្នែកសំខាន់ៗ | ៦០ | ២៥ |
| | ២ | មុខវិជ្ជា និងម៉ោងបង្រៀន នៅសាលាបឋមសិក្សាកម្ពុជា | ៦០ | ២៦ |
| | ៣ | សៀវភៅសិស្ស និងសៀវភៅគ្រូ របស់ក្រសួង ពីថ្នាក់ទី១-៦ | ១៨០ | ២៧ |
| | ៤ | ការគាំទ្រ និងការធ្វើអធិការកិច្ចគ្រូបង្រៀន ពីក្រសួងអប់រំ | ៤៥ | ៣១ |
| | ៥ | ប្រព័ន្ធកម្រងសាលា និងការគាំទ្រគ្រូបង្រៀន | ៤៥ | ៣២ |
| | ៦ | ការគាំទ្រគ្រូបង្រៀន តាមរយៈគំរោងអេស្កាប់ | ២០ | ៣៤ |
| | | | ៦.៥០ | |
| ៤ | ១ | ការបង្ហាញបញ្ជិនៃ*មេរៀន*នៅសាលារៀនរដ្ឋ | ១៥ | ៣៦ |
| | ២ | ការធ្វើអត្ថសញ្ញាណផ្នែកនៃមេរៀន | ៤៥ | ៣៦ |
| | ៣ | ការបង្កើតនូវប្លង់កិច្ចតែងការបង្រៀន ហើយប្រៀបធៀបជាមួយ ប្លង់កិច្ចតែងការគំរូរបស់ក្រសួងអប់រំ | ៧៥ | ៣៨ |
| | ៤ | ការបង្ហាញលំនាំបង្រៀនមេរៀនទី១- គណិតវិទ្យា | ៧៥ | ៣៩ |
| | ៥ | ការបង្ហាញលំនាំបង្រៀនមេរៀនទី២- ភាសាខ្មែរ | ៧៥ | ៤១ |
| | ៦ | ការប្រើប្រាស់សម្ភារដើម្បីជំរុញការបង្រៀន និងរៀន | ៤៥ | ៤២ |
| | | | ៥.៣០ | |
| ៥ | ១ | បច្ចេកទេសបង្រៀនTGL ទី១ (ការសួរសំនួរ) ការសំដែងតួទី១ និងទី២ | ៣០ | ៤៥ |
| | ២ | ការវិភាគជាក្រុម អំពីការសំដែងតួទី១ និងទី២ | ៦០ | ៤៥ |
| | ៣ | ល្បែងសិក្សា-សកម្មភាពសត្វ (អនុវត្តការអាន សំដែងវិនាដកម្ម) | ១៥ | ៤៦ |
| | ៤ | បច្ចេកទេសបង្រៀន TGL ទី១ ការសំដែងតួទី៣ | ៣០ | ៤៦ |
| | ៥ | ការវិភាគជាក្រុម អំពីការសំដែងតួទី៣ | ៦០ | ៤៦ |
| | ៦ | ល្បែងសិក្សា-បកដំឡូងក្តៅ (អនុវត្តការអាន) | ១៥ | ៤៧ |
| | ៧ | កិច្ចការតាមក្រុមតូចៗដើម្បីអនុវត្តបំនិនសរសេរសំនួរ | ៦០ | ៤៧ |
| | ៨ | ការសន្និដ្ឋាន និងការសង្ខេបគំនិតសំខាន់ៗ នៅថ្ងៃទី៥ | ១៥ | ៤៨ |
| | | | ៤.៤៥ | |
| ៦ | ១ | បច្ចេកទេសបង្រៀន TGL ទី២ (ការគ្រប់គ្រងថ្នាក់រៀន) ការសំដែងតួទី១ | ៤៥ | ៤៩ |
| | ២ | ការវិភាគជាក្រុម អំពីការសំដែងតួទី១ | ៤៥ | ៤៩ |
| | ៣ | ល្បែងសិក្សា (លេខក្នុងចិត្ត ការគណនាប្រមាណវិធីទាំង៤) | ១៥ | ៥០ |
| | ៤ | បច្ចេកទេសបង្រៀន TGL ទី២ (ការគ្រប់គ្រងថ្នាក់រៀន) ការសំដែងតួទី២ | ៣០ | ៥១ |

| | | | | |
|---|---|---|---|---|
| | ៥ | ការវិភាគជាក្រុម អំពីការសំដែងតួទី២ | ៤៥ | ៥១ |
| | ៦ | ល្បែងសិក្សា- ដូមីណូ (គណិតវិទ្យា- ការគណនាប្រមាណវិធីទាំង៤) | ៣០ | ៥២ |
| | ៧ | បច្ចេកទេសបង្រៀន TGL ទី២ (ការគ្រប់គ្រងថ្នាក់រៀន) ការសំដែងតួទី៣ | ៤៥ | ៥២ |
| | ៨ | ការវិភាគជាក្រុម អំពីការសំដែងតួទី៣ | ៤៥ | ៥៣ |
| | ៩ | ល្បែងសិក្សា-បង្កើតរូបសត្វដោយប្រើរូបធរណីមាត្រ | ១៥ | ៥៤ |
| | ១០ | អាន និងពិភាក្សា "សិស្សធ្វើការជាក្រុម/ដៃគូ" ដកស្រង់ពី TGL | ៣០ | ៥៤ |
| | ១១ | ការសន្និដ្ឋាន និងការសង្ខេបគំនិតសំខាន់ៗ របស់ថ្ងៃទី៦ | ៤៥ | ៥៥ |
| | | | ៦.៣០ | |
| ៧ | ១ | បច្ចេកទេសបង្រៀន TGL ទី៣ (ការប្រើប្រាស់បរិស្ថាន) ការសំដែងតួទី១ និង ការវិភាគ | ៤៥ | ៥៦ |
| | ២ | ល្បែង-ត្រីជាប់ក្នុងសំណាញ់ | ១៥ | ៥៨ |
| | ៣ | បច្ចេកទេសបង្រៀន TGL ទី៣ (ការប្រើប្រាស់បរិស្ថាន) ការសំដែងតួទី២ | ៦០ | ៥៨ |
| | ៤ | ការវិភាគជាក្រុម អំពីការសំដែងតួទី២ | ៣០ | ៥៩ |
| | ៥ | ការត្រួតពិនិត្យឡើងវិញនូវល្បែងសិក្សាទាំងអស់កន្លងមក | ៣០ | ៥៩ |
| | ៦ | អាន និងពិភាក្សា "ការរៀបចំជាស្រេចដើម្បីចាប់ផ្ដើម និងការស្រូបយកចំណេះដឹងថ្មី" ដកស្រង់ពី TGL | ៣០ | ៦០ |
| | ៧ | ល្បែងសិក្សា- ល្បែងរកពាក្យ (ការបង្កើតពាក្យ សិក្សាពាក្យ) | ១៥ | ៦០ |
| | ៨ | បច្ចេកទេសបង្រៀន TGL ទី៤ (ការប្រើប្រាស់ភាសារបស់កុមារ) សកម្មភាពទី១ | ៣០ | ៦០ |
| | ៩ | បច្ចេកទេសបង្រៀន TGL ទី៤ (ការប្រើប្រាស់ភាសារបស់កុមារ) សកម្មភាពទី២ | ៣០ | ៦១ |
| | ១០ | ការអានៈ " ការប្រើប្រាស់ភាសារបស់កុមារ-កង់" ដកស្រង់ពី TGL | ៣០ | ៦២ |
| | ១១ | ការសន្និដ្ឋាន-ត្រួតពិនិត្យលើបច្ចេកទេសទាំង៤ឡើងវិញ | ៣០ | ៦២ |
| | | | ៥.៤៥ | |
| ៨ | ១ | កញ្ចប់ធនធានសម្ភារសំរាប់គ្រូសហគមន៍ | ៤៥ | ៦៣ |
| | ២ | ល្បែងសិក្សា-បញ្ញត្តិសំខាន់ៗ៣ | ៤៥ | ៦៤ |
| | ៣ | ល្បែងសិក្សាសំរាប់គណិតវិទ្យា | ៩០ | ៦៦ |
| | ៤ | ល្បែងសិក្សាសំរាប់ភាសាខ្មែរ | ៩០ | ៦៧ |
| | | | ៤.៣០ | |

| | | | | |
|---|---|---|---|---|
| ៩ | ១ | តើអ្វីទៅដែលធ្វើអោយក្លាយជាគ្រូបង្រៀនល្អ? សិក្ខាកាមប្រើបទពិសោធន៍ដើម្បីសរសេរអធិប្បាយពីគ្រូម្នាក់ដែលគាត់ចូលចិត្ត | ៤៥ | ៦៩ |
| | ២ | ២.1 គំនិតអំពីបរិស្ថានសាលាកុមារមេត្រី ២.២ សិទ្ធិកុមារ | ៦០ | ៦៩ |
| | ៣ | គ្រូបង្រៀនគឺជាគំរូល្អនៅក្នុងថ្នាក់រៀន | ៣០ | ៧២ |
| | ៤ | អ្នកសិក្សាខុសប្លែកពីគ្នា-ការប្រើប្រាស់វិធីសាស្ត្រប្លែកគ្នា | ៤៥ | ៧៣ |
| | ៥ | ការគ្រប់គ្រងថ្នាក់រៀន-ក្បួនច្បាប់ វិន័យ ការសរសើរ ការស្តីបន្ទោស | ៣០ | ៧៤ |
| | ៦ | ការរៀបចំបន្ទប់រៀនតាមបែបសិស្សមជ្ឈមណ្ឌល | ៤៥ | ៧៥ |
| | ៧ | ការទទួលខុសត្រូវផ្នែករដ្ឋបាលរបស់គ្រូបង្រៀននៅសាលាបឋមសិក្សារដ្ឋ | ៩០ | ៧៦ |
| | ៨ | កិច្ចការគ្រប់គ្រងថ្នាក់រៀន របស់គ្រូបង្រៀន និងសិស្ស | ៣០ | ៧៩ |
| | | | **៦.១៥** | |
| ១០ | ១ | ស្ថាប័នរបស់សាលា និង គោលបំណងរបស់វានៅក្នុងសង្គម | ៣០ | ៨១ |
| | ២ | អ្នកពាក់ព័ន្ធជាមួយសាលារៀន និង បញ្ញតិនៃកម្មសិទ្ធ | ៦០ | ៨១ |
| | ៣ | បញ្ញតិនៃកម្មសិទ្ធិ និងការជំរុញកម្មសិទ្ធិ | ៦០ | ៨៣ |
| | ៤ | ការចូលរួមរបស់សហគមន៍ក្នុងអភិបាលកិច្ចសាលារៀន（គណៈកម្មការទ្រទ្រង់ សាលារៀន（SSC） កម្មវិធីសកម្មភាពជាអាទិភាព（PAP） | ៦០ | ៨៤ |
| | ៥ | អភិបាលកិច្ចល្អ-ការទទួលខុសត្រូវ តម្លាភាព ការចូលរួម | ៦០ | ៨៦ |
| | ៦ | គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ឃុំ（CEFAC） អាជ្ញាធរ និងការអប់រំមូលដ្ឋាន | ៦០ | ៨៨ |
| | ៧ | ការបិទវគ្គបណ្តុះបណ្តាល | ៣០ | ៨៩ |
| | | | **៦.១៥** | |

***ចំណាំ:*** *លេខទំព័រនៅក្នុងឯកសារខាងលើនេះសំរាប់មើលខ្លឹមសារលំអិតនៅក្នុង* ***សៀវភៅសំរាប់អ្នកសម្របសម្រួល*** *ដែលមិនបានជូនភ្ជាប់ទេ។*

# បញ្ជីសម្ភារៈរបស់គ្រូសហគមន៍

| លរ | វត្ថុ | ចំនួន |
|---|---|---|
| ១ | តារាងអក្ខរក្រម | ១ |
| ២ | តារាងចំនួន | ១ |
| ៣ | ផែនទីប្រទេសកម្ពុជា | ១ |
| ៤ | ក្រដាស់រ៉ាមធំ | ១០ សន្លឹក |
| ៥ | ម៉ែត្រខ្សែ(វាស់ខោអាវ) | ៤ |
| ៦ | ជញ្ជីងថ្លឹងដៃ | ១ |
| ៧ | កៅស៊ូកង | ១០០ក |
| ៨ | បំពង់បឺត | ៣៧៥ |
| ៩ | ខ្សែ | ៥០ម |
| ១០ | ដង្កៀបសំរាប់ហាលខោអាវ | ៦០ |
| ១១ | ស្កុត | ១ដុំ |
| ១២ | ដែកគោលមូក | ២ប្រអប់ |
| ១៣ | កន្ត្រៃធំ | ១ |
| ១៤ | កន្ត្រៃតូច | ១ |
| ១៥ | ហ្វឺតក្រដាស (ពណ៌ខ្មៅ) | ៦ |
| ១៦ | ទឹកហ្វឺត (ពណ៌ខ្មៅ) | ១ដប |
| ១៧ | ឃ្នាបគាបក្រដាស | ១ប្រអប់ |
| ១៨ | ឃ្នាបគាបធំ | ១២ |
| ១៩ | ក្រដាសកាតុង | ៤សន្លឹក |
| ២០ | គូល័រឈើ | ៥ប្រអប់ |
| ២១ | ក្តារឆ្នួន | ១០ |
| ២២ | តារាងរដ្ឋបាលទាំង៩ | ១ឈុត |
| ២៣ | តយវាស់ចំណុះ | ១ឈុត |
| ២៤ | បន្ទាត់ផ្លាស្ទិចតូច | ២០ |
|  | ប្រអប់ | ១ |

ត្រួតពិនិត្យដោយសិក្ខាកាម ថ្ងៃទី:..............១០/២០០៥

ឈ្មោះ ......................................

ហត្ថលេខា ......................................

# ទំរង់វាយតំលៃវាយតំលៃពាក់កណ្តាលវគ្គ

*សូមគូសរង្វង់មូលជុំវិញចំលើយដែលអ្នកជ្រើសរើស*

១. ចំពោះខ្ញុំវិញខ្ញុំគិតថាខ្លឹមសារនៃវគ្គបណ្តុះបណ្តាលនេះ

មិនមានប្រយោជន៍ទាល់តែសោះ មានប្រយោជន៍តែផ្នែកខ្លះ មានប្រយោជន៍ស្ទើរតែទាំងអស់ មានប្រយោជន៍ណាស់

២. របៀបរៀននៅក្នុងវគ្គបណ្តុះបណ្តាលនេះធ្វើអោយខ្ញុំមានអារម្មណ៍

ធុញទ្រាន់ណាស់ ធុញទ្រាន់ ធម្មតា ចូលចិត្ត ចូលចិត្តណាស់

៣. របៀបបង្រៀននៅក្នុងវគ្គបណ្តុះបណ្តាលនេះ

មិនមានប្រសិទ្ធិភាពទាល់តែសោះ មានប្រសិទ្ធិភាពតែផ្នែកខ្លះ មានប្រសិទ្ធិភាពស្ទើតែទាំងអស់ មានប្រសិទ្ធិភាពណាស់

៤. ចំនុចចាប់អារម្មណ៍បំផុត ៣ នៅក្នុងវគ្គបណ្តុះបណ្តាលនេះគឺ

១. ........................................................................................................................................

២. ........................................................................................................................................

៣. ........................................................................................................................................

៥. ចំនុចមួយដែលខ្ញុំមិនចូលចិត្តគឺ

................................................................................................................................................

..............................................................................................................................................។

## ទំរង់វាយតំលៃបញ្ចប់សិក្ខាសាលារយៈពេល១០ថ្ងៃ

ឈ្មោះ....................................កំរង:........................................កាលបរិច្ឆេទ:..............................

*សូមបំពេញចំលើយនៅក្នុងចន្លោះដែលបានផ្តល់ជូន*

I. ចំនុចដែលមានប្រយោជន៏បំផុត៣ដែលខ្ញុំបានរៀនក្នុងភាពជាគ្រូសហគមន៏នេះមាន

១. ..................................................................................................................................

២. ..................................................................................................................................

៣. ..................................................................................................................................

II. ចំនុច២ដែលខ្ញុំបានដឹងនៅក្នុងសិក្ខាសាលានេះដែលមិនធ្លាប់រៀនពីមុនមាន

១. ..................................................................................................................................

២. ...................................................................................................................................

IV. គំនិត៣សំរាប់ការបង្រៀនដែលខ្ញុំនឹងព្យាយាមយកទៅប្រើប្រាស់មាន

១. ..................................................................................................................................

២. ..................................................................................................................................

៣. ..................................................................................................................................

V. ចំនុច២ ដែលអេស្កាប់នឹងតាមដានពង្រឹងនៅក្នុងកំឡុងឆ្នាំសិក្សាមាន

១. ..................................................................................................................................

២. ..................................................................................................................................

# តួនាទី និងស្ថានភាពរបស់គ្រូសហគមន៍

*លោក/លោកស្រីដែលជាគ្រូសហគមន៍ទាំងអស់ជាទីគោរពស្រលាញ់ ។*

សូមអបអរសាទ ដែលលោក/លោកស្រីបានបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូសហគមន៍រយៈពេល ១០ថ្ងៃ នេះ។ លោក/លោកស្រីនឹងក្លាយជាគ្រូបង្រៀននៅសាលាបឋមសិក្សាតាមតំបន់របស់ខ្លួនចាប់ពីពេលនេះ តទៅ ។

យើងខ្ញុំសូមជូនពរអោយលោក/លោកស្រីទទួលបាននូវជ័យជំនះលើគ្រប់ភារកិច្ច ។ យើងដឹងហើយ ថាការបង្រៀនគឺជាការងារលំបាកមួយ ហើយជាអាជីពដែលមិនសូវទទួលបាននូវប្រាក់ខែច្រើនទៀតផង ។ ប៉ុន្តែវាគឺជាមោទនភាពមួយដ៏ធំធេងណាស់នៅពេលដែល លោក/លោកស្រីបានឃើញកុមារដែលលោកបាន បង្រៀននោះក្លាយទៅជាពលរដ្ឋល្អមួយរូបដែលទទួលបាននូវការងារដ៏ល្អនៅក្នុងសង្គម ។ លោក/លោកស្រី មានតួនាទីមួយសំខាន់ណាស់ក្នុងការកសាងអនាគតរបស់ប្រទេសកម្ពុជាតាមរយៈការអប់រំកុមារ របស់យើង ។

ដូចនេះវាជាការសំខាន់មួយដែលលោក/លោកស្រីត្រូវយល់អោយបានច្បាស់នូវតួនាទី និងស្ថានភាពជាគ្រូសហគមន៍ ។

១. **ការបំរើការងារនៅក្នុងឆ្នាំសិក្សា ២០០៥-២០០៦** ។ លោក/លោកស្រីគឺជាបុគ្គលិកដែល គ្រប់គ្រងដោយគណៈកម្មការកំរងសាលាមូលដ្ឋាន ឬគណៈកម្មាធិការអប់រំសំរាប់ទាំងអស់ថ្នាក់ឃុំ ។ ដូច្នេះ លោក/លោកស្រីមិនមែនជាបុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡា ឬរដ្ឋាភិបាលកម្ពុជាឡើយ ។

២. **ប្រាក់ឧបត្ថម្ភសំរាប់ខែនិមួយៗក្នុងរយៈពេល៩ខែ** ។ លោក/លោកស្រីនឹងទទួលបានប្រាក់ខែ ដែលផ្តល់ដោយគំរោងអេស្កាប់ចំនួន១៨ដុល្លាក្នុងមួយខែ ។ គំរោងនេះបានទទួលមូលនិធិពី ភ្នាក់ងារជំនួយ របស់សហរដ្ឋអាមេរិកដែលហៅកាត់ថា USAID ។ លោក/លោកស្រីនឹង ទទួលបានប្រាក់ឧបត្ថម្ភដំបូងនៅចុង ខែវិច្ឆិកាឆ្នាំ២០០៥ ។ ក្រោយមកលោក/លោកស្រីនឹងទទួលបាននៅរៀងរាល់ចុងខែរហូតដល់ ខែកក្កដា ឆ្នាំ ២០០៦ ។ ប្រាក់ឧបត្ថម មិនត្រូវបានបើក ជូននៅខែសីហា នឹងខែកញ្ញា ឆ្នាំ២០០៦ទេ ។ ហើយប្រាក់ឧបត្ថម្ភនឹង ត្រូវបានកាត់បើសិនជា អវត្តមានដោយគ្មានការយល់ព្រម ។

៣. **ការបែងចែកកន្លែងធ្វើការងារ** ។ នៅក្នុងកំឡុងថ្ងៃដែលនៅសល់នៅក្នុងខែតុលាឆ្នាំ ២០០៥ នេះអេស្កាប់នឹងពិភាក្សាជាមួយមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាលើការបែងចែកកន្លែងធ្វើការ (ទៅតាមសាលាសម្ព័ន្ធ ឬឧបសម្ព័ន្ធ)និងកំរិតថ្នាក់ដែលត្រូវបង្រៀន ។ លោក/លោកស្រីនឹងទទួលបាននូវ ព័ត៌មាននេះពីនាយកសាលាដែលលោក/លោកស្រីបានចុះហត្ថលេខានៅក្នុងកិច្ចសន្យា ។

៤.	**ការបំរើការងារនៅក្នុងឆ្នាំសិក្សា ២០០៦-២០០៧។** នៅពេលឆ្នាំសិក្សាថ្មី២០០៦-២០០៧ ដែលចាប់ផ្តើមក្នុងខែតុលា លោក/លោកស្រីអាចនឹងទទួលបាននូវកិច្ចសន្យាការងារជាគ្រូ សហគមន៏មួយ ផ្សេងទៀតពីអេស្កាប់។ កិច្ចសន្យានេះធ្វើឡើងដោយអាស្រ័យលើបញ្ហាពីរគឺ ទី១ លោក/លោកស្រីអនុវត្ត ការងារបានល្អជាគ្រូសហគមន៍ និងទី២ ដោយសារមានតំរូវការ បន្តសំរាប់បុគ្គលិកបន្ថែមនៅក្នុងសាលារៀន ក្នុងកំរង។

៥.	**ការបំរើការងារបន្ទាប់ពីឆ្នាំសិក្សា ២០០៦-២០០៧។** អេស្កាប់នឹងផ្តល់ការងារជូនរហូតដល់ចប់ឆ្នាំសិក្សា២០០៦-២០០៧ តែប៉ុណ្ណោះ។

ជាទីបញ្ចប់នេះយើងខ្ញុំសូមអរគុណ លោក/លោកស្រីដែលបានចូលរួមយ៉ាងសកម្មនៅក្នុងវគ្គបណ្តុះបណ្តាល ហើយយើងខ្ញុំរីករាយណាស់ដែលមានឱកាសបានធ្វើការជាមួយលោក/លោកស្រីក្នុងរយៈពេល១០ ថ្ងៃនេះ។ យើងខ្ញុំរំពឹងថានឹងបានទៅសួរសុខទុក្ខ និងជួយលោក/លោកស្រីបន្តទៀតនៅក្នុងកំឡុងឆ្នាំសិក្សា នេះ។

សូមថ្លែងអំណរគុណផងដែរចំពោះមន្ទីរអប់រំខេត្តដែលបានជួយពួកយើងខ្ញុំក្នុងការរៀបចំ ហើយនឹងការផ្តល់នូវសភារៈផ្សេងៗសំរាប់ វគ្គបណ្តុះបណ្តាល។

យើងខ្ញុំដែលជាក្រុមបណ្តុះបណ្តាល សូមជូនពរលោក/លោកស្រីទាំងអស់អោយជួបតែជោគជ័យ និងសេក្តីសុខគ្រប់ប្រការ។

*សូមអរគុណ!*

# ព័ត៌មានអំពីគំរោងអេស្កាប់

## សេចក្តីសង្ខេប ការគាំទ្រសេវាអប់រំសម្រាប់កុមារដែលស្ថិតក្នុងតំបន់ដាច់ស្រយាល

(Educational Support to Children in Underserved Populations ESCUP)

**១. សាវតាទូទៅ:**

- កម្មវិធីនេះបានទទួលថវិកាពី USAID ដើម្បីកែលំអការអប់រំនៅកម្ពុជា ។
- ថវិកាសរុបមាន២លានដុល្លា សំរាប់ប្រតិបត្តិកម្មវិធីរយៈពេល២ឆ្នាំ ដោយមានឱកាសសុំថវិកាបន្ត ប្រសិនបើកម្មវិធីបានជោគជ័យ ។
- ថវិកានេះមកតាមរយៈយន្តកាអេគីប EQUIP ដែលបានជួយរកថវិកាសម្រាប់កម្មវិធីបែបនេះ យ៉ាងលឿន។ វិទ្យាស្ថានអាមេរិកកាំងសម្រាប់ការស្រាវជ្រាវដែលស្ថិតនៅក្នុងទីក្រុងវ៉ាស៊ិនតោនឌីស៊ី គឺជាអង្គការឈានមុខសម្រាប់អេគីប ហើយជាអង្គការដែលបានត្រួតពិនិត្យកម្មវិធីនេះចំពោះ USAID ។
- កម្មវិធីនេះចាប់ផ្តើមពីខែមេសា ឆ្នាំ២០០៥ ដល់ខែមីនា ឆ្នាំ២០០៧។

**២. គោលបំណងរបស់កម្មវិធី:**

- គោលបំណងទូទៅរបស់អេស្កាប់គឺថា បង្កើនភាពងាយស្រួលចូលសាលារៀន និងគុណភាពអប់រំ មូលដ្ឋាន សម្រាប់ក្រុមគោលដៅដែលមិនសូវទទួលបានសេវាអប់រំ ជាពិសេស កុមារក្រីក្រ កុមារពិការ កុមារី និងកុមារដែលមកពីក្រុមជនជាតិភាគតិច ។
- គោលដៅមួយទៀតគឺថាគាំទ្រសិទ្ធិកុមារ ដោយប្រើវិធីសាស្ត្រសាលាកុមារមេត្រី ដែលបានរៀបចំ ដោយក្រសួងអប់រំ យុវជន និងកីឡា ។

**៣. អង្គការដៃគូ:**

- កម្មវិធីសាលាកុមារមេត្រីត្រូវប្រតិបត្តិដោយសហភាព ៣ អង្គការ មានអង្គការអប់រំពិភពលោក ដែលជាអង្គការឈានមុខត្រូវប្រតិបត្តិអន្តរាគមន៍ដោយផ្ទាល់នៅខេត្តក្រចេះ និងខេត្តមណ្ឌលគីរី អង្គកាខេប ជាអង្គការប្រតិបត្តិដោយផ្ទាល់នៅខេត្តកំពង់ចាម និង អង្គការឃែរ ជាអង្គការផ្តល់ បច្ចេកទេសសម្រាប់ រៀបចំអន្តរាគមន៍ចំពោះកុមារជនជាតិភាគតិច ។

**៤. ទំនាក់ទំនងរវាងគោលនយោបាយក្រសួងអប់រំយុវជន និង កីឡា:**

- កម្មវិធីអេស្កាប់គឺជាសាខារបស់កម្មវិធីសាលាកុមារមេត្រី ដែលបានគាំទ្រដោយក្រសួងអប់រំយុវជន និងកីឡា ៥ឆ្នាំកន្លងមកហើយ ។ ដូច្នេះកម្មវិធីនេះគ្មានគណៈកម្មការសម្របសម្រួលដោយឡែកទៀតទេ គឺយើងយក គណៈកម្មការសម្របសម្រួលកម្មវិធីសាលាកុមារមេត្រីតែម្តង។ អេស្កាប់បានសង្ឃឹម ថាការធ្វើបែបនេះនឹង គាំទ្រគ្រឹះគោលនយោបាយ ស្តីពីសាលាកុមារមេត្រីដែលក្រសួងអប់រំយុវជន និងកីឡាបានរៀបចំរួចហើយ ។
- ម្យ៉ាងទៀតកម្មវិធីអេស្កាប់ នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋានអប់រំសម្រាប់ទាំងអស់គ្នា ថ្នាក់ជាតិ ព្រមទាំងគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំដែលអាចមានតួនាទីសំខាន់ក្នុងការរើសនិងគ្រប់គ្រង គ្រូសហគមន៍ ។

## ៥. តំបន់ និងក្រុមគោលដៅ:

- កម្មវិធីនេះត្រូវប្រតិបត្តិនៅ៣ខេត្តគឺ ខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តមណ្ឌលគិរី ។
- កម្មវិធីនេះនឹងផ្តោតទៅលើសាលារៀននៅតំបន់ដាច់ស្រយាល និងក្រុមកុមារដូចតទៅ: កុមារក្រីក្រ កុមារពិការ កុមារី និងកុមារដែលមកពីក្រុមជនជាតិភាគតិច (ជាពិសេស ជនជាតិចាម និងជនជាតិ ដែលនៅតំបន់ភ្នំ ។
- កម្មវិធីអេស្កាប់មានបំណងគាំទ្រ ៨កម្រងសាលារៀននៅខេត្តកំពង់ចាម (ស្រុកត្បូងឃ្មុំ និងស្រុក ពញាក្រែក) ៨កម្រងនៅខេត្តក្រចេះ (ស្រុកសំបូរ និងស្រុកស្នួល) និង១០ទៅ១៥សាលារៀននៅ ខេត្តមណ្ឌលគិរី (ស្រុកកែវសីមា និងស្រុកអូររាំង) ។
- អន្តរាគមន៍ទាំងឡាយក្នុងកម្មវិធីនេះ ត្រូវប្រតិបត្តិក្នុងប្រព័ន្ធអប់រំមូលដ្ឋាន (សាលាបឋមសិក្សានិង អនុវិទ្យាល័យ ។

## ៦. អន្តរាគមន៍ជាក់ស្តែង:

- អន្តរាគមន៍ផ្សេងៗត្រូវបានបែងចែកជា៣ផ្នែកគឺ (១) ការបណ្តុះបណ្តាលគ្រូ (២) ភាពងាយស្រួលចូលសាលារៀន និងគុណភាពអប់រំ (៣) ភាពដៃគូរវាងសាលារៀន និងសហគមន៍ ។
- អន្តរាគមន៍និមួយៗត្រូវបានសម្របសម្រួលទៅតាមផ្នែកដូចតទៅ:

| **ការបំប៉នគ្រូ** | **ភាពងាយស្រួលចូលសាលារៀន និងគុណភាពអប់រំ** | **ការសហការរវាងសាលារៀន និងសហគមន៍** |
|---|---|---|
| 1. អាហារូបករណ៍គរុសិស្ស 12+2 ឬ 9+2 ដែលមកពីមូលដ្ឋានទីតាំងគោលដៅ<br>2. ការបណ្តុះបណ្តាលគ្រូសហគមន៍<br>3. ការគាំទ្របច្ចេកទេសដល់គ្រូដាច់ស្រយាល<br>4. ការបណ្តុះបណ្តាលគ្រូសម្រាប់កម្មវិធីកុមារតូច<br>5. ការបណ្តុះបណ្តាលគ្រូភាសាខ្មែរបន្ថែម<br>6. ការបណ្តុះបណ្តាលអ្នកជំនួយថ្នាក់រៀនពីរភាសា | 7. អាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា<br>៨. អាហារូបករណ៍សសិស្សក្រីក្រអនុវិទ្យាល័យ<br>9.ការបំប៉នសិស្សខ្សោយ<br>10.ការគាំទ្រការប្រតិបត្តិកម្មវិធីកុមារតូច ក្នុងថ្នាក់រៀន (ផ្តល់សម្ភារឬ ឯកសារ ជាដើម )<br>11.បំណិនជីវិតផ្សេងៗ<br>12ការកែលំអហេដ្ឋានរចនាសម្ព័ន្ធ<br>13 ជំនួយផ្នែករាងកាយសម្រាប់សិស្ស ពិការ<br>14 បណ្តាញកុមារជួយកុមារ | 15 បំណិនជីវិតទាក់ទងនឹងវប្បធម៌<br>16 បង្កើតមណ្ឌលវប្បធម៌<br>17 បង្កើតសមាគមយុវជនជនជាតិ<br>18 អ្នកជួយគ្រូចេះ ២ ភាសា<br>19 ការរៀនភាសាខ្មែរបន្ថែមសម្រាប់កុមារជនជាតិ<br>20. សិក្ខាសាលាកំនត់កុមារដែលមិនបានចូលរៀន<br>21. ការគ្រប់គ្រងគ្រូសហគមន៍ |